# សាលក្រមឌុច:

## តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម សំណុំរឿង០០១

### តើយុត្តិធម៌អាចនឹងត្រូវផ្តល់ឱ្យអ្នកទោស១ម៉ឺន៤ពាន់នាក់នៅក្នុងមន្ទីរ ស២១ (គុកទួលស្លែង) ដែរឬទេ?



ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌

មជ្ឈមណ្ឌលឯកសារកម្ពុជា
*ប្រអប់សំបុត្រលេខ ៖ ១១១០*
*ផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ ៖ (៨៥៥)២៣ ២១១ ៨៧៥*
*ទូរសារ ៖ (៨៥៥)២៣ ២១០ ៣៥៨*
*អ៊ីមែល ៖ dccam@online.com.kh*
*គេហទំព័រ ៖ www.dccam.org និង www.cambodiatribunal.org*

# សាលក្រម ឌុច ៖ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម សំណុំរឿង០០១

## តើយុត្តិធម៌អាចនឹងត្រូវផ្តល់ឱ្យអ្នកទោស១ម៉ឺន៤ពាន់នាក់នៅក្នុងមន្ទីរ ស២១ (គុកទួលស្លែង) ដែរឬទេ?

*ជំនួយសប្បុរសធម៌សម្រាប់គម្រោងនេះត្រូវបានផ្តល់ឲ្យដោយសប្បុរសពីការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលកម្ម ក្រសួងការបរទេសសហរដ្ឋអាមេរិក ដោយមានការគាំទ្រពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក និងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ ។*

*រក្សាសិទ្ធិគ្រប់បែបយ៉ាង ឆ្នាំ២០១០ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។*

*រក្សាសិទ្ធិគ្រប់បែបយ៉ាង មិនមានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានយកទៅសរសេរឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬមធ្យោបាយបែបណាក៏ដោយ ដែលរួមមានការថតចម្លង ការកត់ត្រា ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីមជ្ឈមណ្ឌលឯកសារកម្ពុជាបានឡើយ ។*

*គម្រប និងគំនិតសៀវភៅ ៖ ឆាំង យុ*

*របនាសៀវភៅ ៖ អ៊ីវ៉ន រ៉ុង*

*របនាសៀវភៅជាភាសាខ្មែរ ៖ ស៊ឹម សុភ័ក្ត្រ*

*អ្នកបកប្រែ ៖ ហ៊ុយ សម្ផស្ស*

*អត្ថបទ ៖ អាន ហេនឌែល*

*ចំណងជើងរូបថត ៖ កែវ ដាស៊ីល*

*បោះពុម្ពនៅកម្ពុជា*

# តើយុត្តិធម៌អាចនឹងត្រូវផ្តល់ឱ្យអ្នកទោស១ម៉ឺន៤ពាន់នាក់ នៅក្នុងមន្ទីរ ស២១ (គុកទួលស្លែង) ដែរឬទេ?

*សាលក្រមរបស់ ឌុច ពិតជាមិនខុសទេ។*

*ការខឹងសម្បាចំពោះការសម្រេចទោសនេះ មានការកើនឡើងខ្លាំង។ ប្រសិនបើរយៈពេលដែល ឌុច ត្រូវបានឃុំខ្លួនមានចំនួនច្រើនជាងនេះបន្តិចនោះ ប្រហែលជាអាចធ្វើឲ្យជនរងគ្រោះភាគច្រើនមានការពេញចិត្តមិនខាន។ អ្នករស់រានមានជីវិតនឹងពេញចិត្ត ប៉ុន្តែនៅតែគ្មានអ្វីមួយ ឬសាលក្រមណាមួយដែលអាចបំពេញចិត្តដែលបាក់បែករបស់ជនរងគ្រោះទាំងស្រុងនោះទេ។ យើងអាចកាត់ទោស ឌុច ឲ្យជាប់ទោស១ម៉ឺន៤ពាន់ឆ្នាំសម្រាប់ជីវិតរបស់ជនគ្រោះម្នាក់ៗ ហើយទោះបីជាយ៉ាងនេះក្តី ក៏នៅតែមិនយុត្តិធម៌ដដែល។ ដោយទទួលស្គាល់នូវភាពមិនស្របច្បាប់ក្នុងការឃុំខ្លួន ឌុច មុនពេលកាត់ទោសនិងការកាត់បន្ថយទោសជាបន្តបន្ទាប់ភ្លាមៗនោះសាលក្រមរបស់ ឌុច បានផ្តល់ប្រយោជន៍ដល់អ្នករស់រានមានជីវិតទាំងអស់។ សាលក្រមនេះបានផ្តល់ជាគំរូដល់ការកាត់ក្តីប្រកបដោយយុត្តិធម៌នៅកម្ពុជា ឧទាហរណ៍ដូចជាករណីឃុំខ្លួនទាក់ទងនឹងរឿងរំលោភដីធ្លីជាដើម។ ប៉ុន្តែចុងក្រោយ អ្វីដែលសំខាន់នោះគឺមានការទទួលខុសត្រូវជាផ្លូវការមួយ។ ឥឡូវនេះ ការរៀបចំឲ្យមានការផ្សព្វផ្សាយអំពីសាលក្រមដើម្បីជួយឲ្យមានការគាំទ្រតុលាការកាន់តែច្រើន គឺជាការចាំបាច់មុនពេលសំណុំរឿង០០២មកដល់បន្តទៀត ហើយដែលជាការកាត់ក្តីដ៏សំខាន់បំផុតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។*

*ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*



# ជីវប្រវត្តិសង្ខេបរបស់ ឌុច

កាំង ហ្កេកអ៊ាវ ហៅ ឌុច កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវៀយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។ ឌុច ជាកូនប្រុសតែម្នាក់គត់ក្នុងចំណោមបងប្អូនស្រីប្រាំនាក់នៅក្នុងត្រកូលខ្មែរកាត់ចិនមួយ។ ឌុច ចាប់ផ្តើមមានការចាប់អារម្មណ៍លើលទ្ធិកុម្មុយនីសចាប់តាំងពីខ្លួនរៀននៅវិទ្យាល័យ និងថ្នាក់គរុកោសល្យម៉្លេះ។ ឌុច ត្រូវបានចាប់ខ្លួនដោយរដ្ឋាភិបាលសម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៦៨ ដោយសារតែការគាំទ្រសកម្មភាពខ្មែរក្រហម ហើយត្រូវបានចាប់ឃុំឃាំងអស់រយៈពេលជិតពីរឆ្នាំនៅក្នុងគុកព្រៃស។ នៅក្នុងឆ្នាំ១៩៧០ ឌុច ត្រូវបានដោះលែងពីគុកព្រៃសដោយលោកនាយករដ្ឋមន្ត្រី លន់ នល់ ដែលជាផ្នែកនៃការលើកលែងទោសអ្នកជាប់ទោសនយោបាយជាទូទៅមួយ បន្ទាប់ពីសម្តេចព្រះ នរោត្តម សីហនុ ត្រូវបានទម្លាក់ពីតំណែង។ នៅពេលដែល ឌុច រួចចេញពីគុកព្រៃស ឌុច បានចូលរួមជាមួយខ្មែរក្រហមជាថ្មីម្តងទៀត។ នៅប៉ុន្មានឆ្នាំក្រោយមកទៀត ឌុច បានបង្កើត និងមើលការខុសត្រូវគុកខ្មែរក្រហមចំនួនពីរនៅខេត្តកំពង់ស្ពឺ គឺ : មន្ទីរ ម១៣ និង មន្ទីរ ម៩៩ ហើយចាប់ផ្តើមបង្កើនវិធីសាស្ត្រសួរចម្លើយយ៉ាងមានប្រសិទ្ធភាពរបស់ខ្លួន។

មន្ទីរឃុំឃាំង ស-២១ នៅរាជធានីភ្នំពេញត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៥ និងគ្រប់គ្រងដោយ អ៊ិន លន ហៅ ណាត (ដែលមានលេខកូដសម្ងាត់អាយកូមលេខ២១) និង ឌុច ជាអនុប្រធាន។ នៅឆ្នាំ១៩៧៦ ឌុច បានឡើងជាប្រធានរហូតដល់ទីក្រុងភ្នំពេញត្រូវបានកាន់កាប់ដោយវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅខែមករា ឆ្នាំ១៩៧៩។

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានរស់នៅក្នុងចំណោមមេដឹកនាំខ្មែរក្រហមជាច្រើននៅជំរំជនភៀសខ្លួនតាមព្រំដែនថៃរហូតដល់ឆ្នាំ១៩៨៤ នៅពេលដែល ឌុច ត្រូវបានបញ្ជូនទៅបង្រៀនភាសាខ្មែរនៅប្រទេសចិន។ បន្ទាប់ពី ឌុច ត្រឡប់មកវិញ ឌុច បានប្តូរឈ្មោះទៅជា ហង់ ពិន ហើយក្រោយមកក៏ក្លាយជាគ្រូបង្រៀនម្តងទៀតនៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ នៅក្នុងឆ្នាំ១៩៩៥ ផ្ទះរបស់ ឌុច នៅភូមិស្វាយចេក ត្រូវបានមនុស្សមួយក្រុមតូចវាយប្រហារ ហើយប្រពន្ធគាត់ត្រូវបានសម្លាប់ដោយការប៉ុនប៉ងប្លន់ ឬគំនុំសងសឹក។ ឌុច បានផ្លាស់ទៅនៅជាមួយប្អូនស្រីពៅឈ្មោះ ហង់ គីមហុង (ជាពេទ្យ និងជាជំនួយការរបស់ប្រពន្ធឌុច នៅក្នុងសម័យខ្មែរក្រហម) ដែលបច្ចុប្បន្នកំពុងធ្វើជាឆ្មបនៅស្រុកសំឡូត ខេត្តបាត់ដំបង។ នៅក្នុងពេលនោះ ឌុច បានរកឃើញភាពស្ងប់សុខក្នុងគ្រិស្តសាសនា និងចុងក្រោយ ឌុច ក៏បានប្តូរទៅជាគ្រិស្តបរិស័ទ។ ឌុច ត្រូវបានគេស្គាល់អត្តសញ្ញាណ និងត្រូវចាប់ខ្លួននៅសំឡូតនៅឆ្នាំ១៩៩៩ បន្ទាប់មកត្រូវឃុំឃាំងអស់រយៈពេលជាង៨ឆ្នាំ ដោយគ្មានការកាត់ទោសនៅក្នុងគុកតុលាការយោធាកម្ពុជា។ នៅឆ្នាំ២០០៧ ឌុច ត្រូវបានចោទប្រកាន់ និងត្រូវបញ្ជូនទៅមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាតុលាការពិសេសមួយបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩។

**(រូបខាងឆ្វេង) :** ឌុច និង និរសារឈ្មោះ សុខ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៧។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។



# ការកាត់សេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូង

ភស្តុតាងអំពីតួនាទីរបស់ ឌុច នៅក្នុងមន្ទីរឃុំឃាំងស-២១បានបង្ហាញឲ្យដឹងដោយដំណើរការជម្រះក្តីរបស់អង្គជំនុំជម្រះសាលាដំបូង ចាប់តាំងពីខែកុម្ភៈដល់ខែវិច្ឆិកា ឆ្នាំ២០០៩។ នៅក្នុងដំណើរការជម្រះក្តីរបស់ខ្លួននៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ក្នុងនាមជាប្រធានមន្ទីរ ស-២១ ឌុច មិនមែនគ្រាន់តែគ្រប់គ្រងលើមន្ទីរនេះប៉ុណ្ណោះទេ ប៉ុន្តែ ឌុច ក៏មើលការខុសត្រូវបន្ថែមទៀតទៅលើមន្ទីរ ស-២៤(គុកព្រៃសា) ជាជំរំធ្វើការ និងវាលពិឃាតបឹងជើងឯកដ៏គួរឲ្យរន្ធត់។ ឌុច បានអនុវត្តនិងធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រសួរចម្លើយ និងបច្ចេកទេសធ្វើទារុណកម្ម ចេញបញ្ជាឲ្យសម្លាប់ ហើយនិងត្រួតពិនិត្យការសួរចម្លើយអ្នកទោសសំខាន់ៗជាច្រើនដោយផ្ទាល់។

អ្នកទោសដំបូងដែលមកដល់មន្ទីរ ស-២១មុនគេគឺរួមមាន : មន្ត្រីរាជការ និងទាហានដែលជាប់ពាក់ពន្ធ័នឹងរដ្ឋការសម័យ លន់ នល់ ប៉ុន្តែបន្ទាប់មកទៀតមានកម្មាភិបាលខ្មែរក្រហមសំខាន់ៗព្រមទាំងក្រុមគ្រួសាររបស់អ្នកទាំងនោះ ជនបរទេសមានដូចជា ឈ្លើយសឹកវៀតណាម និងកម្មាភិបាលមន្ទីរ ស-២១។ ក្នុងចំណោមអ្នកទោសចុងក្រោយជាច្រើនដែលនាំមកមន្ទីរ ស-២១ កុមារា នង ចាន់ផល មានអាយុ៨ឆ្នាំ ប្អូនប្រុស និងម្តាយរបស់ខ្លួនត្រូវបាននាំមកដល់មន្ទីរឃុំឃាំងនេះ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩។ អ្នកទោសស្ទើរតែទាំងអស់ត្រូវបានធ្វើទារុណកម្មរហូតទាល់តែសារភាពថា ខ្លួនបានប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងបដិវត្តន៍ និងរៀបរាប់ឈ្មោះអ្នកផ្សំគំនិត ដែលអ្នកទាំងនេះត្រូវចាប់ខ្លួនជាបន្តបន្ទាប់ និងសួរចម្លើយបន្តទៀត។ ឌុច បានដឹងថា ចម្លើយសារភាពទាំងឡាយនិងឈ្មោះអ្នករួមគំនិតក្បត់ទាំងប៉ុន្មានដែលខ្លួនបញ្ជូនទៅឲ្យថ្នាក់លើនោះ សុទ្ធតែត្រូវប្រឌិតឡើង។ ឌុច ក៏បានទទួលស្គាល់ដែរថា រាល់អ្នកទោសដែលបានជាប់ឃុំនៅមន្ទីរឃុំឃាំងស-២១ មានជោគវាសនាតែមួយគត់គឺត្រូវគេយកទៅសម្លាប់ដូចគ្នា។ ចំនួនអ្នកទោសដែលត្រូវឃុំឃាំងនៅមន្ទីរ ស-២១មានមិនតិចជាង១២២៧២នាក់ទេ (ឬអាចច្រើនជាងនេះ) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយមានតែអ្នកជាប់ឃុំមួយចំនួនតូចប៉ុណ្ណោះដែលរួចរស់ជីវិត អ្នកទាំងនោះរួមមាន នង ចាន់ផល[១] ប្អូនប្រុសនិងកុមារីបីនាក់អាយុក្រោមបួនឆ្នាំ[២] ។ តួនាទីរបស់ ឌុច នៅក្នុងបទឧក្រិដ្ឋដែលប្រព្រឹត្តនៅមន្ទីរឃុំឃាំងស-២១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឌុច មានទោសពីការទទួលខុសត្រូវក្នុងការដឹកនាំនិងគ្រប់គ្រងទៅលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម (ដែលបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩)។

**(រូបខាងឆ្វេង)** : ឌុច មុនពេលត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៩៩ ដោយកម្លាំងយោធារាជរដ្ឋាភិបាលកម្ពុជា។ ថតដោយ ស្នួត អ៊ីសិត ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១] នៅក្នុងពេលដំណើរការរឿងក្តី ឌុច ដំបូងឡើងបានបដិសេធថា នង ចាន់ផល មិនមែនជាអ្នកជាប់ឃុំនៅមន្ទីរឃុំឃាំងស-២១ (គុកទួលស្លែង)ទេ ដោយសារ ឌុច គិតថារាល់កុមារតូចៗនៅក្នុងគុកនេះត្រូវបានសម្លាប់អស់គ្មានសល់ និងដោយសារតែខ្វះឯកសារបញ្ជាក់ថាម្តាយរបស់ នង ចាន់ផល (លេខឯកសារ K08732) ដែលត្រូវបានឃុំខ្លួននៅទីនោះដែរ។ បន្ទាប់ពីព្រះរាជអាជ្ញាដាក់ជូនឯកសារអំពីជីវប្រវត្តិរបស់ម្តាយ នង ចាន់ផល ជាភស្តុតាង ទើប ឌុច និយាយថា "តាមរយៈតុលាការនេះ ខ្ញុំសុំអភ័យទោសពី នង ចាន់ផល ព្រោះពីមុនខ្ញុំមិនបានទទួលស្គាល់ដោយសារខ្វះឯកសារសម្អាង តែឥឡូវខ្ញុំសូមទទួលស្គាល់ទាំងស្រុង"។ សហព្រះរាជអាជ្ញា និង ឌុច សំណុំរឿង ឌុច ឯកសារសំណុំរឿងលេខ : ០០១/១៨-០៧-២០០៧/ECCC/ TC ប្រតិចារឹកនៃដំណើរការសវនការលើអង្គសេចក្តីនៅលេខ៥ អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩)។

[២] ក្មេងស្រីម្នាក់បានបាត់បង់ជីវិតដោយសារខ្សោះកម្លាំង បន្ទាប់ពីត្រូវបានរកឃើញដោយទាហានវៀតណាមនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩។



# ការដាក់ទោសរបស់អង្គជំនុំជម្រះសាលាដំបូង

មុននឹងសម្រេចទោសកំហុសរបស់ ឌុច អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមវិធានអន្តរជាតិលើករណីបទឧក្រិដ្ឋមុនៗក្នុងការពិចារណាទាំងករណី “ស្ថានទម្ងន់ទោស” និង “ស្ថានសម្រាលទោស” ដើម្បីកំណត់ចំនួនឆ្នាំដែលសមរម្យក្នុងការផ្តន្ទាទោស ឌុច។ ស្ថានទម្ងន់ទោសតម្រូវឲ្យមានការដាក់ទោសរយៈពេលវែង។ អង្គជំនុំជម្រះកត់សម្គាល់ពីភាពគួរឲ្យតក់ស្លុតនិងសាហាវព្រៃផ្សៃនៃបទឧក្រិដ្ឋទាំងនេះ និងការប្រើប្រាស់អំណាចយកទៅប្រព្រឹត្តខុសរបស់ ឌុច និងការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ លើបទឧក្រិដ្ឋដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់ ឌុច ជាច្រើន អនុវត្តលើជនរងគ្រោះដែលមិនមានលទ្ធភាពការពារខ្លួន(រួមទាំងកុមារ)។

អង្គជំនុំជម្រះក៏ពិនិត្យពិចារណាលើស្ថានសម្រាលទោសដើម្បីដាក់ទោសឲ្យតិចជាងទោសជាអតិបរមា គឺជាប់គុកអស់មួយជីវិត។ ទាំងនេះដោយសារតែកិច្ចសហការទូទៅរបស់ ឌុច ជាមួយតុលាការ ការទទួលស្គាល់ ការទទួលខុសត្រូវរបស់ខ្លួន បង្ហាញពីវិប្បដិសារី ហើយកត្តាទាំងនេះមានឥទ្ធិពលទៅលើការផ្សះផ្សាជាតិ ក៏ដូចជាបរិបទបង្ខិតបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងលទ្ធភាពរបស់ ឌុច ក្នុងការស្តារនីតិសម្បទាឡើងវិញបាន។

ក្នុងការពិចារណាទៅលើទំហំនៃករណីទាំងនេះ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា ការសុំទោសរបស់ ឌុច គឺមានកម្រិត។ នៅថ្ងៃទីពីរនៃសវនាការ ឌុច បាននិយាយថា “ខ្ញុំសូមទទួលស្គាល់នូវកំហុសចំពោះបទឧក្រិដ្ឋដែលខ្ញុំបានប្រព្រឹត្តនៅមន្ទីរ ស-២១ ជាពិសេសគឺការធ្វើទារុណកម្ម និងការសម្លាប់មនុស្សនៅទីនោះ”។ ឌុច ក៏បានសុំទោសជនរងគ្រោះនៅមន្ទីរ ស-២១ និងក្រុមគ្រួសាររបស់អ្នកទាំងនោះសុំឲ្យ “បើកនូវផ្លូវមួយឲ្យខ្លួនសុំខមាទោសផង”។ ខណៈពេលដែល ឌុច កំពុងស្វែងរកការកាត់បន្ថយទោស ឌុច ជឿជាក់ថានឹងអាចត្រូវទទួលការអត់ឱនទោសមិនផ្លូវការមួយ ដោយសារតែកិច្ចសហការជាទូទៅ និងការទទួលស្គាល់នូវឯកសារភស្តុតាងនានា។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងពេលសន្និដ្ឋានបញ្ចប់រឿងក្តី សហមេធាវីជាតិរបស់ ឌុច ឈ្មោះ ការ សាវុត្ថ មិនបានយល់ស្របជាមួយដៃគូអន្តរជាតិរបស់ខ្លួនដែលបានលើកឡើងថា ការចោទប្រកាន់ទៅលើ ឌុច ត្រូវតែបញ្ឈប់ ហើយមានន័យថា ឌុច គួរតែត្រូវរួចពីបទចោទ និងត្រូវដោះលែងឲ្យមានសេរីភាព ពីព្រោះ ឌុច មិនមែនជាមេដឹកនាំថ្នាក់ខ្ពស់ខ្មែរក្រហមទេ។ ឌុច ត្រូវបានគេតែងតាំង និងសុំឲ្យអង្គជំនុំជម្រះដោះលែង ឌុច។ ការ សាវុត្ថ បានបញ្ជាក់ថា “ការដោះលែងមានន័យថា ការឲ្យរួចពីបទចោទប្រកាន់”[៤]។ នៅក្នុងការកាត់ក្តីរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងថ្លែងថា :

> ជនជាប់ចោទបានធ្វើការសុំទោសជាសាធារណៈជាច្រើនដង និងបង្ហាញពីវិប្បដិសារីនូវរាល់បទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តនៅពេលដែលគេផ្តល់ឱកាសឲ្យគាត់និយាយ។ យ៉ាងណាមិញ អង្គជំនុំជម្រះរកឃើញថា កត្តាស្ថានសម្រាល

**(រូបខាងឆ្វេង) :** ឌុច ពាក់អាវផ្លាកប៉ូឡូនៅក្នុងពេលកាត់ក្តីនៅក្នុងតុលាការខ្មែរក្រហមឆ្នាំ២០០៩។ ប្រភព : បណ្ណសារដ្ឋានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

៣ សហព្រះរាជអាជ្ញា និង កាំង ហ្កេកអ៊ាវ ហៅ ឌុច ឯកសារសំណុំរឿងលេខ : ០០១/១៨-០៧-២០០៧ /ECCC/TC ប្រតិចារឹកនៃដំណើរការសវនការលើអង្គសេចក្តីនៅលេខ ៦៧-៦៨ (អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩)

៤ សហព្រះរាជអាជ្ញា និង កាំង ហ្កេកអ៊ាវ ហៅ ឌុច ឯកសារសំណុំរឿងលេខ : ០០១/១៨-០៧-២០០៧ /ECCC/TC ប្រតិចារឹកនៃដំណើរការសវនការលើអង្គសេចក្តីនៅលេខ ៦២ អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩)











***រូបផ្នែកលើខាងឆ្វេង*** *: សារ៉ា ថូម៉ាស (នៅចុងខាងឆ្វេង) ទីប្រឹក្សាខាងក្រុមជំនួយការជនរងគ្រោះនៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្ដឹង ការីម ខាន់ (នៅចំកណ្ដាលក្នុងសម្លៀកបំពាក់អាវធំ)។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបចំកណ្ដាលខាងឆ្វេង*** *: ព្រះសង្ឃ និងអ្នកភូមិកំពុងតែទស្សនាការប្រកាសសាលក្រម ឌុច នៅវត្តកោងកាង ខេត្តប៉ៃលិន នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបផ្នែកក្រោមខាងឆ្វេង*** *: អ្នកភូមិនៅក្នុងវេទិកាពិភាក្សាប្រព្រឹត្តទៅនៅព្រះវិហារកាតូលិកសំឡូត ក្នុងភូមិអូរស្នួត ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង។ វេទិកាពិភាក្សានេះចាប់ផ្ដើមបន្ទាប់ពីការទស្សនាការប្រកាសសាលក្រម ឌុច នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបនៅខាងស្ដាំ*** *: ព្រះសង្ឃកំពុងតែអានសៀវភៅចំណងជើងថា "ប្រល័យពូជសាសន៍ : តើនរណាជាមេដឹកនាំខ្មែរក្រហមដែលត្រូវកាត់ទោស? សារសំខាន់នៃសំណុំរឿង០០២" នៅវត្តកោងកាង ខេត្តប៉ៃលិន នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។ រូបថត : កែវ ដាស៊ីល។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបផ្នែកក្រោមខាងស្ដាំ*** *: ព្រះវិហារកាតូលិកនៅក្នុងស្រុកសំឡូត ខេត្តបាត់ដំបង ជាព្រះវិហារកាតូលិកដែល ឌុច បានប្ដូរឲ្យខ្លួនទៅជាគ្រិស្តបរិស័ទវិញ។*

*ទោសដោយផ្អែកលើការបង្ហាញពីវិប្បដិសារីរបស់គាត់មិនទទួលបានជោគជ័យទេ នៅពេលដែល ឌុច ខកខានមិនបានទទួលស្គាល់ពេញលេញ និងច្បាស់លាស់ពីការទទួលខុសត្រូវរបស់ខ្លួន។ ដោយឡែកនៅក្នុងឱកាសថ្លែងជាលើកចុងក្រោយជនជាប់ចោទស្នើចៅក្រមឲ្យលើកលែងបទចោទប្រកាន់ដែលផ្ទុយទាំងស្រុងទៅនឹងការទទួលស្គាល់ និងការសោកស្ដាយរបស់ ឌុច ពីមុន ដែលអាចនឹងជួយសម្រាលទោសរបស់ខ្លួន។*[៥]

*ដោយពិចារណាលើបញ្ហាទាំងអស់នេះ ទើបអង្គជំនុំជម្រះបានសម្រេចទោស ឌុច ឲ្យជាប់គុក៣៥ឆ្នាំ។ ក្រោយមកចំនួនឆ្នាំដែលខ្លួនជាប់ទោសត្រូវបានកាត់បន្ថយ៥ឆ្នាំ ដើម្បីជាសំណងនូវការឃុំខ្លួនខុសនីតិវិធីដោយតុលាការយោធាអស់ជិត៨ឆ្នាំដែលផ្ទុយនឹងច្បាប់ជាតិ។ អង្គជំនុំជម្រះពិចារណាឃើញថា ឌុច បានជាប់ឃុំអស់រយៈពេល១១ឆ្នាំហើយ ដូច្នេះ ឌុច នៅសល់រយៈពេលជាប់ឃុំ១៩ឆ្នាំទៀត ទើបគ្រប់ចំនួនទោស៣០ឆ្នាំ។*

# បណ្ដឹងសាទុក្ខ

*ភ្លាមៗបន្ទាប់ពីសាលក្រមបានប្រកាស មេធាវីការពារក្ដី ឌុច ឈ្មោះ ការ សាវុត្ថ បានប្រកាសថា ខ្លួននឹងប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អំណះអំណាងដំបូងរបស់ ការ សាវុត្ថ គឺថានៅក្នុងតួនាទីផ្លូវការ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយ ឌុច ក៏មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតលើបទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរ បើដូច្នេះ ឌុច មិនគួរត្រូវបានបញ្ចូលទៅក្នុងចំណោមមនុស្សដែលត្រូវកាត់ទោសទេ។ ព្រះរាជអាជ្ញាក៏កំពុងតែប្ដឹងឧទ្ធរណ៍ពីរយៈពេលនៃការឃុំខ្លួនរបស់ ឌុច ពីព្រោះព្រះរាជអាជ្ញាជឿថា ការសម្រេចក្ដីរបស់អង្គជំនុំជម្រះសាលាដំបូង “ផ្ដល់នូវការថ្លឹងថ្លែងមិនសមរម្យទៅលើបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងររបស់ ឌុច និងតួនាទីរបស់គាត់ ហើយនិងមានបំណងចូលរួមនៅក្នុងបទឧក្រិដ្ឋទាំងនោះ”។ គេក៏ជឿជាក់ដែរថា អង្គជំនុំជម្រះថ្លឹងថ្លែងមិនបានសមរម្យទៅលើស្ថានសម្រាលទោស។ ជាចុងក្រោយ ព្រះរាជអាជ្ញាកំពុងប្ដឹងឧទ្ធរណ៍ពីការកំណត់ចរិតលក្ខណៈនៃបទឧក្រិដ្ឋរបស់អង្គជំនុំជម្រះ ព្រោះព្រះរាជអាជ្ញាជឿថា “អង្គជំនុំជម្រះខកខានមិនបានឆ្លុះបញ្ចាំងពីទំហំដ៏ធំធេងនៃបទឧក្រិដ្ឋដែល ឌុច បានប្រព្រឹត្ត”។*

*អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាទៅលើអំណះអំណាងទាំងនេះ ហើយគេសង្ឃឹមថា សេចក្ដីសម្រេចនេះនឹងត្រូវប្រកាសនៅក្នុងអំឡុងពាក់កណ្ដាលឆ្នាំ២០១១។ យោងតាមច្បាប់របស់តុលាការ អង្គជំនុំជម្រះនេះមានយុត្តាធិការសម្រេចឲ្យ ឌុច ផុតពីការចោទប្រកាន់ ឬក៏កាត់បន្ថយ ឬបង្កើនចំនួនឆ្នាំនៃការដាក់ទោស ដោយយោងទៅលើការរកឃើញអង្គច្បាប់និងអង្គហេតុ។*

*៥ សហព្រះរាជអាជ្ញា និង កាំង ហ្គេកអ៊ាវ ហៅ ឌុច ឯកសារសំណុំរឿងលេខ : ០០១/១៨-០៧-២០០៧ /ECCC/TC ប្រតិចារឹកនៃដំណើរការសវនាការជម្រះក្ដី (អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០)។*







***(រូបផ្នែកលើខាងឆ្វេង)*** *: រ៉ូប៊ឺត ហាមីល ជនជាតិ ណូវែលហ្សេឡង់ កំពុងកាន់ផ្កាឈូកមួយបាច់នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។ ពិធីបុណ្យបង្សុកូលមួយធ្វើឡើងដើម្បីគោរព វិញ្ញាណក្ខន្ធជនរងគ្រោះ ១ម៉ឺន៤ពាន់នាក់នៅគុកទួលស្លែង។ បងប្រុសរបស់ ហាមីល ឈ្មោះ កែរី ហាមីល ត្រូវជាប់ឃុំនិងសម្លាប់នៅក្នុងគុកនេះនៅឆ្នាំ១៩៧៨។ ថតនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០ ថតដោយ កែវ ដាស៊ីល។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបផ្នែកលើខាងស្តាំ*** *: លោក នង ចាន់ផល អាយុ៤០ឆ្នាំ និងកូនស្រី នង ចាន់អមរា កំពុងអុជធូប នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០។ នង ចាន់ផល ជាកុមារាក្នុងចំណោមកុមារប្រាំនាក់ដែលរួចរស់ជីវិតពីគុកទួលស្លែង។ នៅក្នុងចំណោមអ្នកទោស១ម៉ឺន៤ពាន់នាក់ ដែលត្រូវបានបញ្ជូនទៅឃុំឃាំងក្នុងគុកទួលស្លែង មានតែអ្នកទោសមួយចំនួនតូចប៉ុណ្ណោះដែលអាចរួចរស់ជីវិត។ នង ចាន់ផល បាននៅស្ងៀមមិននិយាយពីការជាប់ទោសនៅទីនោះរហូតដល់ឆ្នាំ២០០៨។ នៅឆ្នាំ២០០៩ នង ចាន់ផល បានចុះឈ្មោះធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅសាលាក្តីខ្មែរក្រហម ប៉ុន្តែត្រូវបានបដិសេធចោលដោយសាលាក្តី។ ថតដោយ : កែវ ដាស៊ីល។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបខាងក្រោម*** *: អាឡាំង វ៉ែនណឺ (ចំកណ្តាល) មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជានៃសាលាក្តី ខ្មែរក្រហម។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។*

# គម្រោងឯកសាររស់

គម្រោងឯកសាររស់ដែលដឹកនាំដោយ ស៊ីវិ សាវីណា រៀបចំឡើងដើម្បីលើកទឹកចិត្តឲ្យមានការចូលរួមរបស់ប្រជាជនទូទៅនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងបំណងជួយអ្នកស្រុក អ្នកភូមិដែលជាជនរងគ្រោះឲ្យយល់ដឹងកាន់តែច្បាស់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងដំណើរការច្បាប់ផ្សេងៗរបស់តុលាការ។ ចាប់តាំងពីដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមក្នុងឆ្នាំ២០០៧មក គម្រោងនេះបានអញ្ជើញប្រជាជនប្រមាណជាង១ម៉ឺននាក់ ដែលរួមមានមេឃុំ១ពាន់៥រយនាក់ និងទូន ហាកិម មេដឹកនាំប្រជាជនចាមដែលកាន់សាសនាអ៊ីស្លាមមកកាន់ទីក្រុងភ្នំពេញ ដើម្បីទទួលការបណ្តុះបណ្តាលផ្នែកច្បាប់ អង្កេតពីដំណើរការសាលាក្តី និងការចូលរួមជជែកពិភាក្សាពីអ្វីដែលគាត់បានឃើញ។ លើសពីនេះទៀត គម្រោងនេះបានបើកវេទិកាពិភាក្សាអំពីអង្គជំនុំជម្រះ។ ពេលថ្មីៗនេះ គម្រោងនេះក៏បានផ្សាយបន្តផ្ទាល់ និងបញ្ចាំងឡើងវិញពីការប្រកាសសាលក្រម ឌុច នៅប្រាំបីខេត្ត ដើម្បីប្រមូលប្រតិកម្មទៅនឹងសាលក្រម និងលើកទឹកចិត្តឲ្យមានការពិភាក្សាទៅលើអត្ថន័យរបស់សាលក្រម ឌុច មុនពេលការកាត់ទោស នួន ជា ខៀវ សំផន អៀង សារី និង អៀង ធីរិទ្ធ នៅឆ្នាំ២០១១ ដែលជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិត។ គម្រោងឯកសាររស់នេះនឹងបន្តបើកវេទិកាពិភាក្សាអំពីអង្គជំនុំជម្រះនៅតាមអតីតតំបន់ដែលកាន់កាប់ដោយខ្មែរក្រហមជាបន្តបន្ទាប់ទៀត។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង :
ស៊ីវិ សាវីណា តាមរយៈអ៊ីមែល : truthsavina.s@dccam.org
ទូរស័ព្ទ : ០១២ ៦៨ ៨០ ៤៦





**រូបខាងឆ្វេង** : ស៊ីវិ សាវីណា កំពុងនិយាយទៅកាន់អ្នកភូមិអំពីសាលក្រម ឌុច នៅវត្តកោងកាង ខេត្តប៉ៃលិន នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។ ថតដោយ កែវ ដាស៊ីល ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។ **រូបខាងស្តាំ** : មេឃុំម្នាក់បានសួរសំណួរទៅ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងវេទិកាពិភាក្សានៅព្រះវិហារកាតូលិកសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០។ ថតដោយ : កែវ ដាស៊ីល។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។













***រូបផ្នែកលើខាងឆ្វេង*** *: បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា គឹម សុវណ្ណដានី អែម ឆាត និង សុខ វណ្ណៈ បង្ហាញពីបដាដែលចងនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ បដានេះមានន័យថា "ការប្រកាសសាលក្រម កាំង ហ្គេកអ៊ាវ ហៅ ឌុច នឹងចាប់ផ្តើមនៅវេលាម៉ោង១០ព្រឹក ថ្ងៃច័ន្ទ ខែកក្កដា ឆ្នាំ២០១០"។ ថតដោយ វ៉ាន់ថាន់ ពៅដារ៉ា ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបផ្នែកកណ្តាលខាងឆ្វេង:*** *ក្មេងប្រុសកំពុងបើកសៀវភៅប្រល័យពូជសាសន៍ "តើអ្នកណាជាមេដឹកនាំខ្មែរក្រហមដែលត្រូវកាត់ទោស? សារសំខាន់នៃសំណុំរឿង០០២" និងទស្សនាវដ្តីស្វែងរកការពិត នៅវត្តកោងកាង ខេត្តប៉ៃលិន នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។ ថតដោយ : កែវ ដាស៊ីល។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបផ្នែកខាងក្រោម*** *: ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសួរអ្នកចូលរួមស្ត្រីម្នាក់ឲ្យអានកថាខណ្ឌនៅក្នុងព្រះគម្ពីរយ៉េស៊ូ បន្ទាប់ពីគាត់អានខ្លឹមសារលោកុប្បត្តិទំព័រទី៩:៦ "អ្នកណាដែលកំចាយឈាមរបស់មនុស្សនោះ ឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ។ ត្បិតព្រះទ្រង់បានបង្កើតមនុស្សឲ្យដូចជារូបទ្រង់"។ នៅក្នុងព្រះវិហារកាតូលិកសំឡូតនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០។ ថតដោយ : កែវ ដាស៊ីល។ ប្រភព :បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។* ***រូបថតខាងស្តាំពីលើចុះក្រោម*** *: ដើមបណ្តឹងរដ្ឋប្បវេណីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហាវ សោភា ម៉ាន សូត សិន ស៊ីណែត។ ថតដោយ : កែវ ដាស៊ីល ។ ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។*

## ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា

### ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| ល.រ | ឈ្មោះ | ភេទ | ទំនាក់ទំនងទៅនឹងជនរងគ្រោះនៃមន្ទីរ ស-២១ | មុខងារ |
|---|---|---|---|---|
| ១ | ហាវ សោភា | ស្រី | ត្រូវជាកូនស្រីរបស់ជនរងគ្រោះឈ្មោះ ចិន សៀ ហៅ ហាវ ហាន | កសិករ |
| ២ | ឆៃ ហ៊ាប | ប្រុស | ត្រូវជាប្អូនប្រុសរបស់ជនរងគ្រោះឈ្មោះ ឆៃ ហេង | កសិករ |
| ៣ | ម៉ាន់ សុត | ប្រុស | ត្រូវជាឪពុករបស់ជនរងគ្រោះឈ្មោះ ម៉ាន ស៊ីម ហៅ វៀម | កសិករ |
| ៤ | ង៉ែត សុខ | ស្រី | ត្រូវជាប្អូនស្រីរបស់ជនរងគ្រោះឈ្មោះ ណុប សរ ហៅ ង៉ែត ង៉ែម | កសិករ |
| ៥ | ធីម៉ូធី ស្កុត ឌីត | ប្រុស | ត្រូវជាប្អូនប្រុសរបស់ជនរងគ្រោះឈ្មោះ ម៉ៃឃីល ឌីដ | សមាជិកនាវិក |
| ៦ | យឹម ឡេង | ប្រុស | ត្រូវជាកូនរបស់ជនរងគ្រោះឈ្មោះ ឆ្លក លួន ហៅ យ៉ន | កសិករ |
| ៧ | អ៊ុម ពិសិដ្ឋ | ប្រុស | ត្រូវជាសិទ្ធិវន្តរបស់ប្រពន្ធគាត់ឈ្មោះ សួស សារិន ដែលបានបាត់បង់បងស្រីនៅមន្ទីរ ស-២១ ឈ្មោះ សួស សុវណ្ណ | កសិករ |
| ៨ | កែ ខុន | ប្រុស | ត្រូវជាប្អូនប្រុសរបស់ជនរងគ្រោះឈ្មោះ កែ កេងស៊ី | កសិករ |
| ៩ | កែ សាម៉ូត | ស្រី | ត្រូវជាប្អូនស្រីរបស់ជនរងគ្រោះឈ្មោះ កែ កេងស៊ី | កសិករ |
| ១០ | ស៊ិន ស៊ីណែត | ស្រី | ត្រូវជាចៅស្រីរបស់ជនរងគ្រោះឈ្មោះ ភាច គឹម ហៅ ស៊ិន | អ្នកស្ម័គ្រចិត្តសុខភាពភូមិ |
| ១១ | រូន ស្រីណុប | ស្រី | ត្រូវជាប្អូនស្រីរបស់ជនរងគ្រោះឈ្មោះ រូន ម៉ាត់ ហៅ សាវី | អ្នកនេសាទ |
| ១២ | អែល លីម៉ះ | ស្រី | ត្រូវជាប្អូនស្រីរបស់ជនរងគ្រោះឈ្មោះ អ៊ីស្មាអ៊ែល អាម៉ាត់ ហៅ សុខ | កសិករ |
| ១៣ | ស្មាន ស | ស្រី | ជាបងស្រីរបស់ជនរងគ្រោះឈ្មោះ ស្មាន ស្លេះ ហៅ ឡេង សុខា និងជាម្តាយរបស់ សា ម៉ាត់ | មេផ្ទះ |
| ១៤ | ស្មាន ណុប | ស្រី | ត្រូវជាបងស្រីរបស់ជនរងគ្រោះឈ្មោះ ស្មាន ស្លេះ ហៅឡេង សុខា និងជាអ៊ីរបស់សា ម៉ាត់ | មេផ្ទះ |
| ១៥ | ម៉ែន ឡាយ | ស្រី | ត្រូវជាម្តាយរបស់ជនរងគ្រោះឈ្មោះ មិន កាន | |
| ១៦ | ញ៉ែម សុផាន | ស្រី | ត្រូវជាប្អូនស្រីរបស់ជនរងគ្រោះឈ្មោះ ញ៉ែម ចុល ហៅ វ៉ា | កសិករ |
| ១៧ | នេត ផល្លី | ប្រុស | ត្រូវជាប្អូនប្រុសជនរងគ្រោះឈ្មោះ របស់ នេត ប៊ុនធី | កសិករ |
| ១៨ | ម៉ាន មះ ហៅ ម៉ាន ម៉ាលីម៉ះ | ស្រី | ត្រូវជាម្តាយរបស់ជនរងគ្រោះឈ្មោះ តា ឡុសម៉ាត់ ហៅ ម៉ាន ម៉ាត់ | មេផ្ទះ |
| ១៩ | កុំ មេន ហៅ គុម មេន | ស្រី | ត្រូវជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ ស្រី យ៉េង | មេផ្ទះ |
| ២០ | ទ្រី ង៉ិចលាង | ស្រី | ត្រូវជាប្អូនស្រីរបស់ជនរងគ្រោះឈ្មោះ ឃឿង ប៊ុយស៊័រ | កសិករ |
| ២១ | ហេង ង៉ិចហុង | ស្រី | ត្រូវជាកូនរបស់ជនរងគ្រោះឈ្មោះ សុក ហេង | លក់ដូរ |
| ២២ | បេង ចាន់ថន | ប្រុស | ត្រូវជាប្អូនប្រុសរបស់ជនរងគ្រោះឈ្មោះ បេង ពុំ | កសិករ |
| ២៣ | យុន ឈឺន | ប្រុស | ត្រូវជាពូរបស់ជនរងគ្រោះឈ្មោះ យុន លឿន | កសិករ |
| ២៤ | លី ឃៀក | ប្រុស | ត្រូវជាបងប្រុសរបស់ជនរងគ្រោះឈ្មោះ អួយ វ៉ែន ហៅ ម៉ៅ | កសិករ |
| ២៥ | ពូល ពន្លឺក ហៅ ង៉ែត | ប្រុស | ត្រូវជាកូនរបស់ជនរងគ្រោះឈ្មោះ ពូល ទឿន ហៅ ចាំង | បុគ្គលិកធនាគារជាតិនៃកម្ពុជា |
| ២៦ | ចាន់ គ្រួច | ប្រុស | ត្រូវជាប្អូនប្រុសរបស់ជនរងគ្រោះឈ្មោះ ចាន់ នួន ហៅ ស៊ីនួន | កសិករ |
| ២៧ | នង គឹមល្មៀង* | ស្រី | ជាប្អូនស្រីរបស់ជនរងគ្រោះឈ្មោះ នង គឹមហ្គេច ហៅ នង គឹមវ៉េត | លក់ដូរ |
| ២៨ | រ៉ូប៊ីត ហាមីល | ប្រុស | ត្រូវជាប្អូនប្រុសរបស់ជនរងគ្រោះឈ្មោះ ឃែរី ហាមីល | អ្នកគ្រប់គ្រងកម្មវិធី និងវាគ្មិន |

### ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | | | | |
|---|---|---|---|---|
| ១ | | | | កសិករ |
| ២ | លី ហ៊ា | ប្រុស | អតីតអ្នកទោសមន្ទីរ ស-២១ | លក់ដូរ |
| ៣ | សួន សៀង* | ប្រុស | ត្រូវជាបងប្រុសរបស់ជនរងគ្រោះឈ្មោះ ប៉ែន យន, ប៉ែន អុំ, និងប៉ែន អ៊ុន | កសិករ |
| ៤ | ង៉ែត អ៊ុយ | ស្រី | ត្រូវជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ ប្រាក់ ប៉ាត | កសិករ |
| ៥ | ឆៀវ នាប ហៅ ខៀវ នាប | ស្រី | ត្រូវជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ ហេង ជឿន | កសិករ |
| ៦ | លឹម យ៉ុន | ស្រី | ត្រូវជាបងស្រីរបស់ជនរងគ្រោះឈ្មោះ ម៉ា ឃិទ្ធ | កសិករ |
| ៧ | ចេហ្វ្រី ជេម | ប្រុស | ត្រូវជាក្មួយប្រុសរបស់ជនរងគ្រោះឈ្មោះ ជេម វីល្លៀម ភ្លាក | |
| ៨ | នង សារ៉ាត់ | ប្រុស | ត្រូវជាបងប្អូនជីដូនមួយរបស់ជនរងគ្រោះឈ្មោះ នង សារ័ត្ន | កសិករ |
| ៩ | យ៉ូស៊ូ វ៉តស័ឆាល | ប្រុស | ត្រូវជាក្មួយប្រុសរបស់ជនរងគ្រោះឈ្មោះ ជេម វីល្លៀម ភ្លាក | តម្រួត |

## មេធាវីដើមបណ្តឹងសំណុំរឿង ០០១

ការីម ខាន់ (អង់គ្លេស) អាឡាំង វ៉ែនណឺ (ស្វីស) ទី ស្រីនណា(កម្ពុជា) និង ប្រ៊ីនី ម៉ាកហ្គនីហ្គល ជាអ្នកតំណាងឲ្យជនរងគ្រោះ៣៧នាក់ ដែលជួយគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាដែលចូលរួមដោយផ្ទាល់នៅក្នុងសំណុំរឿង០០១។ ក្នុងចំណោមអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានដើមបណ្តឹងចំនួន២៨ត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណីដោយអង្គជំនុំជម្រះនៅក្នុងការសម្រេចក្តីជាលើកចុងក្រោយ។ ការីម ខាន់ មានបទពិសោធន៍ការងារខាងបណ្តឹងតវ៉ាក្តី និងការពារក្តីនៅក្នុងតុលាការអន្តរជាតិជាច្រើនជាង១៨ឆ្នាំ រួមទាំងតុលាការឧក្រិដ្ឋកម្មអន្តរជាតិអតីតយូហ្គោស្លាវីនិងរវាន់ដា តុលាការឧក្រិដ្ឋកម្មអន្តរជាតិតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន បទឧក្រិដ្ឋកម្មធ្ងន់ធ្ងរពិសេសនៅទីម័រខាងកើត តុលាការពិសេសសម្រាប់លីបង់ (អ្នកផ្តល់ប្រឹក្សា)។ ការីមធ្វើជាអ្នកដឹកនាំមេធាវីការពារឲ្យលោក ឆាល ថៃលរ័ ដែលជាអតីតប្រធានាធិបតី លីបេរីយ៉ា និងជាប្រធានស្ថាក្តីឲ្យ ហ្សង់ពៀ បែមបា និង ជាប្រធានស្ថាក្តីឲ្យ បាហា អាយឌ្រីស អាប៉ូហ្គាដា ហើយបច្ចុប្បន្នកំពុងតែដឹកនាំមេធាវីការពារនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ទាំង អាបដូលា បានដា និង សាឡា ចែបូ សហស្ថាក្តីអន្តរជាតិ អាឡាំង វ៉ែនណឺ បានធ្វើការក្នុងផ្នែកច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិចាប់តាំងពីឆ្នាំ២០០៣ ហើយក្នុងធ្វើការជាមេធាវីតវ៉ាក្តីស្មុគស្មាញជាច្រើននៅតុលាការពិសេសសម្រាប់សៀរ៉ាឡេអូនរួមទាំងរឿងក្តីនានារបស់ ឆាល ថៃល័រ។ សហមេធាវី ប្រ៊ីនី ម៉ាកហ្គនីហ្គល(អាមេរិក) ជាមេធាវីដែលមានសមត្ថភាព និងជាគ្រូបង្រៀននៅសាកលវិទ្យាល័យ អ៊ុយទ្រិច ប្រទេសហូឡង់ ដែលមានជំនាញខាងដោះស្រាយបញ្ហារបស់ជនរងគ្រោះនៅក្នុងតុលារអន្តរជាតិនានា។ សហមេធាវីជាតិ ទី ស៊ីនណា ធ្វើការទាក់ទងទាំងច្បាប់រដ្ឋប្បវេណីនិងច្បាប់ឧក្រិដ្ឋចាប់តាំងពីឆ្នាំ២០០៥ រួមទាំងផ្នែកជំនួយការច្បាប់កម្ពុជាផងៗ

"យើងមិនចង់បានការសងឈាម ប៉ុន្តែយើងត្រូវការយុត្តិធម៌"
ការីម ខាន់





**រូបពីឆ្វេងទៅស្តាំ :** ការីម ខាន់ អាឡាំង វ៉ែនណឺ និង ទី ស៊ីនណា។ ប្រភព : អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

# ដើម្បីការចងចាំ និង យុត្តិធម៌

***រូបថតនៅលើគម្រប :*** *វិហារកាតូលិកមួយធ្វើអំពីឈើនៅភូមិអូរស្វូត ឃុំតាសាញ់ ស្រុកសំឡូត ខេត្តបាត់ដំបង។ សហគមន៍កាតូលិកនៅស្រុកសំឡូតនេះបានបង្កើតឡើង និងឧបត្ថម្ភដោយខ្មែរអាមេរិកាំង ឈ្មោះ គ្រីស្តូហ្វឺ ឡាប៉េល ដែលប្រឹងប្រែងផ្លាស់ប្តូរសាសនាប្រជាជនខ្មែរទូទាំងប្រទេសរួមទាំង ភាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រធានគុកទួលស្លែង។ ស្រុកសំឡូតមានប្រជាជនដែលជាអតីតខ្មែរក្រហមជាច្រើនដែលចូលរួមចលនាតស៊ូក្នុងអំឡុងពេលសង្គ្រាមនៅតាមទល់ដែនថៃ បន្ទាប់ពីខ្មែរក្រហមត្រូវបាត់បង់អំណាចនៅក្នុងឆ្នាំ១៩៧៩ ហើយអ្នកទាំងអស់នោះទើបតែអាចរស់នៅក្នុងសន្តិភាពពិតប្រាកដនៅក្នុងឆ្នាំ១៩៩៩ ខណៈដែលស្រុកនេះបានក្លាយទៅជាស្រុកដែលគ្រប់គ្រងដោយខ្មែរក្រហមចុងក្រោយ ហើយដែលចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា។ រូបថត : កែវ ដាស៊ីល។*